ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

ក្រសួងមហាផ្ទៃ

លេខ : ០១១ សណន

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០០៨

# សេចក្តីណែនាំ
# ស្តីពី
# បែបបទ និង នីតិវិធីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

យោងមាត្រា១៦ មាត្រា៣៧ និងមាត្រា៣៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មាត្រា២ នៃអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ និងអនុលោមតាមប្រការ៣០ នៃប្រកាសលេខ១៨៨៤ ប្រ.ក ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០២ ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្រុង ក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់។

ក្រសួងមហាផ្ទៃ សូមធ្វើការណែនាំអំពីបែបបទ និងនីតិវិធីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដូចតទៅ ៖

អនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា១៦ នៃច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អាចផ្លាស់ប្តូរបានទៅតាមករណីណាមួយ ដូចខាងក្រោម ៖

១-សាមីខ្លួនទទួលមរណភាព

២-សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច

៣-សាមីខ្លួនសុំលាលែងជាលាយលក្ខណ៍អក្សរពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

៤-សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ

៥-សមាជិកត្រូវបានបណ្តេញចេញដោយប្រព្រឹត្តផ្ទុយនឹងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៨៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

៦-សាមីខ្លួនត្រូវបានបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

ដើម្បីធានាឱ្យការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ តាមករណីនីមួយៗខាងលើបានទាន់ពេលវេលាកំណត់នោះ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងអាជ្ញាធរពាក់ព័ន្ធនានា ដូចខាងក្រោម ៖

ន

១-មេឃុំ ចៅសង្កាត់ត្រូវរៀបចំសំណើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាលាយលក្ខណ៍អក្សរមកក្រសួងមហាផ្ទៃតាមរយៈអភិបាលស្រុក ខណ្ឌ និងអភិបាលខេត្ត ក្រុង តាមករណីនីមួយៗ ដូចខាងក្រោម ៖

- ករណីមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបណាមួយបានទទួលមរណភាពសំណើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបនោះត្រូវមានភ្ជាប់មកជាមួយនូវសេចក្តីចម្លងសំបុត្រមរណភាពដែលចេញឱ្យដោយអាជ្ញាធរមានសមត្ថកិច្ច។

- ករណីមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបណាមួយបានបាត់បង់សម្បទាវិជ្ជាជីវៈសំណើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបនោះត្រូវមានភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ពីការបាត់បង់សម្បទាវិជ្ជាជីវៈពីក្រសួង ស្ថាប័នមានសមត្ថកិច្ច។

- ករណីមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបណាមួយលាឈប់ពីមុខតំណែងសាមីខ្លួនរូបនោះត្រូវផ្ញើលិខិតសុំលាលែងជាលាយលក្ខណ៍អក្សរស្នើទៅក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន។ សំណើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សារូបនោះត្រូវមានភ្ជាប់មកជាមួយនូវលិខិតសុំលាលែងពីមុខតំណែងរបស់សាមីខ្លួន(ឧបសម្ព័ន្ធ១)។

- ករណីមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបណាមួយត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយសំណើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបនោះត្រូវមានភ្ជាប់មកជាមួយនូវសាលក្រមស្ថាពរពីស្ថាប័នតុលាការ។

- ករណីមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបណាមួយដែលបានប្រព្រឹត្តខុសពីបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់ តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៨៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ហើយត្រូវបានក្រុមប្រឹក្សាឃុំ សង្កាត់នោះធ្វើការប្រជុំអនុម័តបណ្តេញចេញពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។ សំណើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបនោះត្រូវមានភ្ជាប់មកជាមួយនូវរបាយការណ៍ និងកំណត់ហេតុស្តីពីការប្រជុំអនុម័តបណ្តេញសមាជិកក្រុមប្រឹក្សាចេញពីក្រុមប្រឹក្សាឃុំ សង្កាត់។ ក្នុងករណីកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីអនុម័តបណ្តេញសមាជិកណាម្នាក់ដែលត្រូវបានដឹកនាំដោយមន្ត្រីដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃសំណើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំស្នើឡើងដោយអង្គភាពសាមីនៃមន្ត្រីដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដោយភ្ជាប់មកជាមួយនូវកំណត់ហេតុប្រជុំជូនក្រសួងមហាផ្ទៃដោយផ្ទាល់តែម្តងពុំចាំបាច់ស្នើដោយមេឃុំ ចៅសង្កាត់ឡើយ។

- ករណីមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបណាមួយត្រូវបានបញ្ឈប់ពីសមាជិកនៃ

គណបក្សនយោបាយរបស់ខ្លួន គណបក្សនយោបាយសាមីត្រូវធ្វើសេចក្តីរាយការណ៍ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់នោះដោយត្រូវមានភ្ជាប់មកជាមួយនូវលិខិត ឬសេចក្តីសម្រេចរបស់គណបក្សនយោបាយនោះស្តីពីការបញ្ឈប់ជននោះពីគណបក្សនយោបាយស្របតាមលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងនៃគណបក្សនយោបាយសាមី ។ សំណើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់សម្រាប់ករណីនេះត្រូវមានភ្ជាប់មកជាមួយនូវលិខិត ឬ សេចក្តីសម្រេចស្តីពីការបញ្ឈប់ជននោះពីគណបក្សនយោបាយ។

ការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់តាមករណីនីមួយៗខាងលើនេះមេឃុំ ចៅសង្កាត់ក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនត្រូវបញ្ជូនសំណើសុំផ្លាស់ប្តូរនេះទៅសាលាស្រុក ខណ្ឌសាមីក្នុងរយៈពេលយ៉ាងយូរពីរ(០២)ថ្ងៃបន្ទាប់ពីទទួលពាក្យស្នើសុំតាមករណីនីមួយៗ (ឧបសម្ព័ន្ធ២) និងត្រូវចម្លងជូនសាមីគណបក្សនយោបាយនៃសមាជិកក្រុមប្រឹក្សាដែលត្រូវផ្លាស់ប្តូរនោះមួយច្បាប់។

**២**-អភិបាលស្រុក ខណ្ឌ ត្រូវធ្វើការពិនិត្យសំណើសុំផ្លាស់ប្តូរនេះដោយត្រូវតែធ្វើការផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវនូវឯកសារយោង ឬ ឯកសារពាក់ព័ន្ធនានាដូចដែលបានកំណត់តាមករណីនីមួយៗក្នុងរយៈពេលយ៉ាងយូរមួយ(០១)ថ្ងៃបន្ទាប់ពីបានទទួលសំណើសុំផ្លាស់ប្តូរពីមេឃុំ ចៅសង្កាត់។ ករណីពិនិត្យឃើញថាសំណើសុំផ្លាស់ប្តូរមានភាពត្រឹមត្រូវ អភិបាលស្រុក ខណ្ឌត្រូវចារបញ្ជូនសំណើនេះទៅអភិបាលខេត្ត ក្រុងសាមី។ ករណីពិនិត្យឃើញថាសំណើសុំផ្លាស់ប្តូរមានភាពមិនត្រឹមត្រូវ អភិបាលស្រុក ខណ្ឌត្រូវបញ្ជូនសំណើត្រឡប់ទៅសាលាឃុំ សង្កាត់ដោយធ្វើការបញ្ជាក់ជាលាយលក្ខណ៍អក្សរឱ្យបានជាក់លាក់នូវភាពមិនត្រឹមត្រូវនោះដើម្បីឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើការកែសម្រួលឡើងវិញភ្លាម។

៣-អភិបាលខេត្ត ក្រុង ត្រូវចាត់ឱ្យធ្វើការពិនិត្យសំណុំឯកសារនៃសំណើផ្លាស់ប្តូរនេះឱ្យបានម៉ត់ចត់ និងត្រឹមត្រូវរួចហើយត្រូវធ្វើការផ្ទៀងផ្ទាត់ជាមួយសមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់ពេលប្រកាសសុពលភាព ឬ ប្រកាសប្តូរសមាសភាពសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់របស់គណបក្សនយោបាយណាមួយដែលមានការពាក់ព័ន្ធជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលត្រូវស្នើសុំផ្លាស់ប្តូរក្នុងរយៈពេលយ៉ាងយូរមួយ(០១)ថ្ងៃបន្ទាប់ពីបានទទួលឯកសារសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាពីអភិបាលស្រុក ខណ្ឌសាមី។ ប្រសិនបើសំណុំឯកសារនៃសំណើផ្លាស់ប្តូរនេះមានលក្ខណៈត្រឹមត្រូវអភិបាលខេត្ត ក្រុងត្រូវចំណារលើសំណើសុំផ្លាស់ប្តូរនោះរួចហើយបញ្ជូនសំណើនោះមកក្រសួងមហាផ្ទៃ(នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន)ជាបន្ទាន់ ។

ប្រសិនបើសំណុំឯកសារនៃសំណើផ្លាស់ប្តូរមានលក្ខណៈពុំទាន់ត្រឹមត្រូវ  អភិបាលខេត្ត ក្រុងត្រូវធ្វើការបញ្ជាក់ជាលាយលក្ខណ៍អក្សរឱ្យ បានជាក់លាក់នូវភាពមិនត្រឹមត្រូវនោះភ្ជាប់ជាមួយសំណើសុំផ្លាស់ប្តូរនោះបញ្ជូនត្រឡប់ទៅសាលាឃុំ  សង្កាត់វិញដើម្បីឱ្យធ្វើការកែសម្រួលជាបន្ទាន់។

ទន្ទឹមនឹងការពិនិត្យសំណុំឯកសារនៃសំណើផ្លាស់ប្តូរនេះដែរ  អភិបាលខេត្ត  ក្រុងត្រូវចាត់ឱ្យធ្វើការពិនិត្យបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ  សង្កាត់របស់គណបក្សនយោបាយដែលមានអាសនៈក្នុងក្រុមប្រឹក្សាឃុំ  សង្កាត់នៃខេត្ត ក្រុងរបស់ខ្លួន។  ក្នុងការពិនិត្យនេះក្នុងករណីពិនិត្យឃើញបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយបានរំកិលលេខរៀងអស់បេក្ខជន  ឬនៅសល់បេក្ខជនបម្រុង២  ឬ៣នាក់  អភិបាលខេត្ត  ក្រុងត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រសួងមហាផ្ទៃជាបន្ទាន់  ដើម្បីក្រសួងមហាផ្ទៃស្នើទៅគណៈកម្មការជាតិរៀបចំការបោះឆ្នោតចាត់ចែងតាមច្បាប់  បទបញ្ជា  និងនីតិវិធី ។

សេចក្តីណែនាំនេះត្រូវអនុវត្តជំនួសសេចក្តីណែនាំលេខ  ០០៩ស.ណ.ន  ចុះថ្ងៃទី២៩  ខែមេសា  ឆ្នាំ២០០២  ស្តីពីបែបបទ  និងនីតិវិធីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ  សង្កាត់។

ទទួលបានសេចក្តីណែនាំនេះអភិបាលគ្រប់ខេត្ត  ក្រុងត្រូវធ្វើការផ្សព្វផ្សាយណែនាំដល់ក្រុមប្រឹក្សាឃុំ  សង្កាត់នៃខេត្ត  ក្រុងរបស់ខ្លួន  និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព។

**ឧបនាយករដ្ឋមន្ត្រី  រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង

<u>កន្លែងទទួល</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គណៈកម្មការជាតិរៀបចំការបោះឆ្នោត
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា  រដ្ឋសភា
- គណបក្សនយោបាយពាក់ព័ន្ធ
  (ដើម្បីជូនជ្រាប)
- សាលាខេត្ត  ក្រុង
- សាលាស្រុក  ខណ្ឌ
- សាលាឃុំ  សង្កាត់
  (ដើម្បីអនុវត្ត)
- ឯកសារ  កាលប្បវត្តិ